ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
TRUST REGULATOR

និយ័តករបរធនបាលកិច្ច
លេខ: ០០១/២២ ន.ប.ធ/ក.ព.៣.

*ថ្ងៃព្រហស្បតិ៍ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២*

## សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃអង្គារ ៩ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ និយ័តករបរធនបាលកិច្ច (ន.ប.ធ) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងវិសោធនកម្មប្រកាសស្តីពី “**កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច**” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

កិច្ចប្រជុំពិគ្រោះយោបល់នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបាននូវធាតុចូល និងមតិយោបល់បន្ថែមពីវិស័យឯកជន និងបុគ្គលពាក់ព័ន្ធនានា ដើម្បីឱ្យការរៀបចំប្រកាសនេះទទួលបាននូវភាពគ្រប់ជ្រុងជ្រោយសំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ចនេះ និងឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។

កិច្ចប្រជុំពិគ្រោះយោបល់នេះ មានអ្នកចូលរួមពីតំណាងបរធនបាលនៃបរធនបាលកិច្ចចុះបញ្ជី, តំណាងក្រុមហ៊ុនគ្រប់គ្រងមូលនិធិ, ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបុគ្គលពាក់ព័ន្ធផ្តល់សេវានៅក្នុងវិស័យបរធនបាលកិច្ច។

**និយ័តករបរធនបាលកិច្ច**

អាសយដ្ឋាន ៖ អគារ ១៦៨F (ជាន់ទី៨) សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ : (+៨៥៥)២៣-៦៣៨-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh